ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

# អត្ថប្រយោជន៍
# នៃការបង់ពន្ធ




ប៉ារៀបចំអីវ៉ាន់ច្រើនយ៉ាងនេះ យើងគិតទៅលេងឯណា ប៉ា?
ថ្ងៃនេះយើងគិតនាំគ្នា ទៅលេងផ្ទះលោកតា លោកយាយខាងម៉ាក់ម្តង!
មែនឬអី ប៉ា?
មែនហើយកូន! ឡើងឡានទៅ
MART
ប៉ាឈប់ចូលរកទិញអ្វីទុក ឱ្យកូនញ៉ាំក្នុងឡានបន្តិច!
កូន ចង់ញ៉ាំអី រើសមើលខ្លួនឯងចុះ!
ចាស ប៉ា!


មួយកញ្ចប់ ១០ ០០០៛
អ៊ីចឹងយកពីរកញ្ចប់សិន
នេះលោក! វិក្កយបត្រ
ប៉ា! នំពីរកញ្ចប់ ពេលកូនរើសកូនចាំថា
មួយកញ្ចប់ថ្លៃ ១០ ០០០៛ ហេតុអ្វីក៏
ពីរកញ្ចប់សរុបទៅថ្លៃ ២២ ០០០ រៀល?
នៃកូន នំពីរកញ្ចប់ថ្លៃតែ ២០ ០០០៛ ទេ
តែយើងត្រូវបង់អាករលើតម្លៃបន្ថែម ២០០០៛ ទៀត!


ប៉ា! អ្វីទៅជាអាករ
លើតម្លៃបន្ថែម?
អាករលើតម្លៃបន្ថែមគឺជា
ប្រភេទពន្ធប្រយោល
ដែលរាជរដ្ឋាភិបាលកំណត់
លើទំនិញឬសេវាដែលយើង
ប្រើប្រាស់រាល់ថ្ងៃ។ ប្រទេសនានា
លើសកលលោកក៏គេកំណត់
ពន្ធប្រភេទនេះលើការទិញ
ទំនិញនិងសេវាដែរ។
រាជរដ្ឋាភិបាលបានប្រាក់ពីការបង់ពន្ធ-អាកររបស់
យើងនេះហើយ ដែលអាចមានលទ្ធភាពកសាង
ហេដ្ឋារចនាសម្ព័ន្ធដែលក្នុងនោះរួមមានផ្លូវថ្នល់ ស្ពាន
កំពង់ផែ ជាដើម ដើម្បីគាំទ្រ និងជំរុញកំណើនសេដ្ឋកិច្ច
ព្រមទាំងផ្តល់ប្រាក់បៀវត្សដល់មន្ត្រីរាជការ
គ្រប់ស្ថាប័ន រួមទាំងប្រាក់ខែប៉ាផង ដើម្បីផ្តល់
សេវាសាធារណៈដល់ប្រជាជនយើង។
បង់ចេះតែបង់ហើយ តែមិនដឹងជាខាង
ពន្ធដារហ្នឹងយកលុយទៅណាខ្លះទេ?
អូនកុំចេះតែនិយាយស្មានអ៊ីចឹង ប្រាក់ពន្ធដែលយើងបានបង់
គឺចូលទៅក្នុងធនាគារហើយបញ្ជូនបន្តទៅរតនាគារជាតិដែល
ជាឃ្លាំងប្រាក់របស់រដ្ឋ។ រៀងរាល់ឆ្នាំក្រសួងសេដ្ឋកិច្ច និង
ហិរញ្ញវត្ថុបានរៀបចំច្បាប់ថវិកាសម្រាប់ចំណូល
និងចំណាយយ៉ាងល្អិតល្អន់។


អូនឃើញទេ ស្ពានឆ្លងទន្លេនៅខាងមុខយើងនេះពីពេលមុន ប្រសិនបើស្ទះ ត្រូវរង់ចាំស្រឡាង ៣ ទៅ ៤ ម៉ោងទើបឆ្លងបាន ប៉ុន្តែឥឡូវនេះយើងអាចឆ្លងទៅមកបានយ៉ាងស្រួលដោយពុំចាំបាច់រង់ចាំ


រដ្ឋមានថវិកាគ្រប់គ្រាន់សម្រាប់សាងសង់ផ្លូវថ្មីបន្ថែមទៀត ព្រមទាំងសាងសង់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនានា សំដៅបម្រើសេវាសុខភាពដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន




កាលពីមុន ប្រជាកសិករយើង ស្ទើរតែទាំងស្រុង ធ្វើស្រែដោយពឹងផ្អែក
លើទឹកភ្លៀង ដែលធ្វើឱ្យពួកគាត់មានការលំបាក ព្រមទាំងប្រមូលផល
បានតិច។រាជរដ្ឋាភិបាលបាននិងកំពុងសាងសង់ប្រព័ន្ធធារាសាស្ត្រដែល
ផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋយើងក្នុងការប្រកបរបរកសិកម្ម។
ការអភិវឌ្ឍទាំងអស់នេះគឺសុទ្ធសឹងតែប្រើប្រាស់ថវិការដ្ឋដែលបានមកពី
ការរួមចំណែកបង់ពន្ធរបស់យើងគ្រប់គ្នា។


សាលាឃុំ
ម្យ៉ាងវិញទៀត នៅតាមឃុំ សង្កាត់នីមួយៗ រាជរដ្ឋាភិបាលបានទម្លាក់
ថវិកា តាមរយៈថវិកាថ្នាក់ក្រោមជាតិ ដើម្បីសាងសង់សាលាឃុំថ្មីដែល
បង្កលក្ខណៈងាយស្រួល ក្នុងការផ្តល់សេវាដល់ប្រជាជន ព្រមទាំង
អភិវឌ្ឍផ្លូវថ្នល់ នៅក្នុងភូមិ ឃុំ ឱ្យបានកាន់តែល្អប្រសើរ។


បងឈប់បន្តិចសិន! ឈប់
នៅមាត់ច្រកសាលានោះ
ខ្ញុំចាំថា ធ្លាប់បានរៀនថ្នាក់
អនុវិទ្យាល័យនៅសាលានេះ
កាលពីជាង១០ឆ្នាំមុន។
ពេលនោះ វាគឺជាសាលាដែលមានដំបូលប្រក់ក្បឿង
និងមានជញ្ជាំងធ្វើអំពីឈើពុកផុយខ្លះទៅហើយ
តែពេលនេះខ្ញុំមើលលែងចង់ស្គាល់ ព្រោះសាលា
មានអគារកម្ពស់ពីរជាន់យ៉ាងថ្មីសន្លាង។
ស្អាតណាស់ ម៉ាក់!


យើងជិតដល់ផ្ទះលោកតា លោកយាយហើយកូន
អូនឃើញទេ? សូម្បីតែនៅទីរួមខេត្ត ក៏មាន សួនច្បារ សម្រាប់ឱ្យប្រជាជនមកលំហែកម្សាន្ត មិនចាញ់ទីក្រុងភ្នំពេញប៉ុន្មានដែរ។ នេះគឺបានមកពីថវិកាថ្នាក់ក្រោមជាតិ ដែលអាជ្ញាធរមូលដ្ឋានបាន អភិវឌ្ឍសម្រាប់តម្រូវការរបស់ប្រជាពលរដ្ឋ។
នេះនែ! ដល់ផ្ទះលោកតា លោកយាយល្មម។ អ្ហ៎! លោកតា លោកយាយទើបបណ្តើរគ្នាមកពីណាអ៊ីចេះ?
ជម្រាបសួរ ប៉ា! ម៉ាក់! រួចចុះ ប៉ាម៉ាក់ទើបអញ្ជើញមកពីណាហ្នឹង? បណ្តើរគ្នាទាំងទឹកមុខញញឹមទៀត។
ជម្រាបសួរ! លោកតា លោកយាយ


អូហ៍ ម៉ាក់និងប៉ា ទើបមកពីបង់ពន្ធអចលនទ្រព្យ ព្រោះផ្ទះយើងស្ថិតនៅទីរួមខេត្ត ដូច្នេះយើងក៏ត្រូវមានកាតព្វកិច្ចបង់ពន្ធដែរ។
បង់អស់ប៉ុន្មានទៅប៉ា ?
វាមិនច្រើនប៉ុន្មានទេកូន ប៉ុន្តែវាជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូប ដើម្បីរួមចំណែកក្នុងថវិកាជាតិ
កូនឃើញទេ ? មិនត្រឹមតែប៉ាកូនទេដែលយល់ដឹងពីកាតព្វកិច្ចបង់ពន្ធ សូម្បីតែលោកតាលោកយាយក៏យល់ដឹងច្បាស់ណាស់ដែរ។
ការចូលរួមបង់ពន្ធ
គឺជា
ការចូលរួមអភិវឌ្ឍ
ប្រទេសជាតិ

This document was produced with the financial assistance of the European Union and SIDA.